**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**

លេខ: ៧០៥/ន.៣
/២០១៥

# សេចក្តីប្រកាសជូនពត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម រដ្ឋមន្ត្រីការពារជាតិម៉ាឡេស៊ី ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អមដំណើរដោយ មេដឹកនាំ ADSOM ព្រមទាំងសមាជិកប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជានឹងអញ្ជើញទៅចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានក្រៅផ្លូវការ (ADMM Retreat) និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូកលើកទី៣ (3rd ADMM-Plus) ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី០២-០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅទីក្រុងកូឡាឡាំពួរប្រទេសម៉ាឡេស៊ី។

ក្រោមទិសស្លោក "អាស៊ាន៖ ការរក្សាសន្តិសុខ និងស្ថេរភាពតំបន់សម្រាប់ប្រជាជន និងតាមរយៈប្រជាជន" រដ្ឋមន្ត្រីការពារជាតិអាស៊ានទទួលស្គាល់នូវសារៈសំខាន់នៃប្រជាជន ក៏ដូចជាថ្នាក់ដឹកនាំក្នុងការតម្រង់ទិសនៃនិម្មាបនកម្មសន្តិសុខតំបន់ ដោយធ្វើចលនាឆ្ពោះទៅរកប្រជាជនថ្នាក់កណ្តាលរបស់អាស៊ាន។ កិច្ចប្រជុំនេះ នឹងបម្រើវេទិកាសម្រាប់រដ្ឋមន្ត្រីការពារជាតិអាស៊ានផ្លាស់ប្តូរទស្សនៈស្តីពីស្ថានការណ៍សន្តិសុខថ្មីៗ និងបច្ចុប្បន្នភាពស្តីពីសកម្មភាពនានា ក្រោមក្របខ័ណ្ឌADMM និងADMM-បូក។ កិច្ចប្រជុំ ADMM Retreat នឹងធ្វើជាសាក្សីក្នុងការផ្ទេរ-ប្រគល់នៃប្រធាន ADMM ពីម៉ាឡេស៊ីជូនទៅសាធារណៈរដ្ឋប្រជាមានិតុប្រជាធិបតេយ្យឡាវ។

ភ្នំពេញ,ថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៥